សម្ព័ន្ធទន្លេកម្ពុជា
The Rivers Coalition in Cambodia

INTERNATIONAL RIVERS
people • water • life

# គម្រោងវារីអគ្គិសនីដនសាហុង

គម្រោងវារីអគ្គិសនីដនសាហុង (Don Sahong) ដែលបានគ្រោងឡើង គឺស្ថិតនៅលើខ្សែទឹកមេនៃទន្លេមេគង្គនៅក្នុងតំបន់ស៊ីផាន់ដនភាគខាងត្បូងប្រទេសឡាវ នៅជិតពីរគីឡូម៉ែត្រខាងលើខ្សែទឹកនៃព្រំដែន ឡាវ-កម្ពុជា។ ទំនប់ដនសាហុងគម្រាមកំហែងការប្រកបរបរចិញ្ចឹមជីវិតនិងជលផលដ៏សម្បូណ៌បែបក្នុងមូលដ្ឋាននៅក្នុងប្រទេសឡាវ និង អាចមានផលប៉ះពាល់ផងដែរលើជលផលនៅក្នុងប្រទេសកម្ពុជា ថៃឡង់ដ៏ និង វៀតណាម ទន្ទឹមគ្នានឹងផលវិបាកចំពោះសន្តិសុខស្បៀងនិងសេដ្ឋកិច្ចនៃតំបន់នេះ។ លើសពីនេះទៀត ដោយធ្វើឱ្យខូចខាតដល់ហ្វូងត្រីផ្សោត Irrawaddy ចុងក្រោយនៅក្នុងប្រទេសឡាវ ក៏ដូចជាការបង្វែរទឹកពីជ្រោះផាផេង ទំនប់ដនសាហុងអាចធ្វើឱ្យខូចខាតដល់កំណើនប្រជាប្រិយភាពនៃតំបន់នេះជាតំបន់គោលដៅទេសចរណ៍មួយ។

## សាវតារ និង សេចក្តីអធិប្បាយអំពីគម្រោង

នៅស៊ីផាន់ដន (ដែលត្រូវគេស្គាល់ផងដែរថាជាល្បាក់ខោន) ទឹកទន្លេមេគង្គធ្លាក់ចុះប្រហែល ពី ២០ ទៅ ៣០ ម៉ែត្រ តាមព្រែកតូចៗហូរខ្លាំងខ្វាត់ខ្វែងដែលហូរត្របាញ់គ្នានៅក្នុងចំណោមកោះជាច្រើននៃតំបន់នេះ។ ទំនប់ដនសាហុងដែលបានស្នើឡើងនេះ នឹងស្ថិតនៅខាងចុងក្រោមខ្សែទឹកនៃព្រែកហ៊ូសាហុងដែលមានប្រវែងប្រហែលប្រាំពីរគីឡូម៉ែត្រនៅចន្លោះកោះធំៗដនសាហុងនិងដនសាដាំ (សូមមើលផែនទី)។ ទំនប់នេះនឹងមានកំពស់ពី ៣០ ទៅ ៣២ ម៉ែត្រ និង ផលិតអគ្គិសនីពី ២៤០ ដល់ ៣៦០ ម៉េហ្គាវ៉ាត់ ដែលភាគច្រើនសម្រាប់នាំចេញទៅកាន់ប្រទេសថៃនិងកម្ពុជា។



*ល្បាក់ខោនផាផេង ដែលគឺជាកន្លែងទេសចរដ៏ពេញនិយមមួយនៅស៊ីផាដោន* *(Carl Middleton, International Rivers)*

ក្រុមហ៊ុនអភិវឌ្ឍន៏គម្រោង ពោលគឺក្រុមហ៊ុន Mega First Corporation Berhad (MFCB) គឺជាក្រុមហ៊ុនវិស្វកម្មនិងសំណង់ម៉ាឡេស៊ីមួយ។ កាលពីខែ មីនា ឆ្នាំ ២០០៦ MFCB បានចុះអនុស្សរណៈនៃការយោគយល់ (MoU) មួយជាមួយរដ្ឋាភិបាលឡាវដើម្បីរៀបចំធ្វើការសិក្សាលទ្ធភាពគម្រោង។ បន្ទាប់មក ក្នុង ខែ កុម្ភៈ ឆ្នាំ ២០០៨ កិច្ចព្រមព្រៀងអភិវឌ្ឍន៏គម្រោងមួយត្រូវបានចុះហត្ថលេខា

ដែលអនុញ្ញាតឱ្យ MFCB ឈានចូលដល់ការចរចារទុំជោរ និង បញ្ចប់បង្ហើយព័តិមានលម្អិតនៃគម្រោងជាមួយរដ្ឋាភិបាលឡាវ និង មុខសញ្ញាអ្នកទិញអគ្គិសនី ដែលត្រូវធ្វើមុនដំណាច់ខែ កញ្ញា ឆ្នាំ ២០០៩។

## ផលប៉ះពាល់របស់គម្រោង

*ជលផល*

តំបន់សស៊ីផាន់ដនមានឈ្មោះល្បីល្បាញអំពីជលផលដ៏សម្បូណ៌បែបរបស់ខ្លួន ដែលមានប្រភេទត្រីដែលគេស្គាល់យ៉ាងហោចណាស់ចំនួន ២០១ ប្រភេទ ដែលនៅក្នុងនោះ ប្រភេទត្រីជាច្រើនមានតម្លៃពាណិជ្ជកម្មខ្ពស់។ តំបន់នេះត្រូវបានទទួលស្គាល់ដោយអ្នកវិទ្យាសាស្រ្តថាគឺជាច្រកចង្អៀតដ៏សំខាន់មួយពេញៗមួយឆ្នាំសម្រាប់ការបំលាស់ទីកន្លែងរបស់ត្រីនៅក្នុងអាងទន្លេមេគង្គក្រោមទាំងមូល ដែលអ្នកភូមិក្នុងមូលដ្ឋានរកទទួលទានលើការប្រមូលផលត្រីដ៏សម្បូណ៌បែប។

ខណៈដែលការរៀបចំប្លង់ចុងក្រោយនៃគម្រោងដនសាហុងមិនទាន់បានផ្សព្វផ្សាយជាសាធារណៈនៅឡើយ ទំនប់នេះត្រូវបានគេរាយការណ៍ថា មុខជាបង្កើតទំនប់មួយនៅលើព្រែកហ៊ូសាហុងទាំងមូល។ ព្រែកនេះមានសារៈសំខាន់បំផុតនៅក្នុងតំបន់ស៊ីផាន់ដនសម្រាប់ឱ្យត្រីធ្វើបំលាស់ទីកន្លែង ជាពិសេស នៅក្នុងរដូវប្រាំង។ ទំនប់ដនសាហុងគម្រាមកំហែងលើរបៀបធ្វើបំលាស់ទីកន្លែងរកចំណី និង បន្តពូជរបស់ត្រីច្រើនប្រភេទ រួមទាំងការធ្វើបំលាស់ទីកន្លែងធំៗរវាងប្រទេសឡាវនិងកម្ពុជាផងដែរ ដែលមុខជាប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើជលផលសំខាន់ៗស្ទើរតែទាំងអស់នៃភាគខាងត្បូងប្រទេសឡាវ (សូមមើលប្រអប់ ទំព័រ ៤)។ ផលប៉ះពាល់នៃទំនប់ដនសាហុងលើត្រីនិងជលផលអាចប៉ះពាល់ប្រជាជនរាប់សែននាក់ដែលរស់នៅតាមដងទន្លេមេគង្គ និង ដៃទន្លេមេគង្គ នៅក្នុងទូទាំងភាគខាងត្បូង និង ភាគកណ្តាលប្រទេសឡាវ ក៏ដូចជានៅប្រទេសកម្ពុជា វៀតណាម និង ថៃឡង់ដ៏ផងដែរ។




**សំណើទីតាំងនៃ**
**ទំនប់ដនសាហុង**

ទោះបីជាព័ត៌មានប្លង់លម្អិតនៅមិនទាន់បានផ្សព្វផ្សាយជូនសាធារណៈជននៅឡើយក្តី ក៏ជម្រើសសម្រាលផលប៉ះពាល់លើជលផលដែលអាចកើតឡើង រួមមានច្រកត្រីឆ្លងកាត់មួយ ឬ ការធ្វើឱ្យព្រែកជិតខាងកាន់តែជ្រៅតាមរយៈការបំផ្ទុះបំបែកថ្ម។ ប៉ុន្តែ លទ្ធភាពជោគជ័យនៃជម្រើសទាំងពីរនេះ នៅមានមន្ទិលច្រើន។ ដោយលើកឡើងពីកត្តាអេកូឡូស៊ី និង កម្រិតខ្ពស់នៃបំលាស់ទីកន្លែងត្រី មជ្ឈមណ្ឌលមច្ឆាជាតិពិភពលោក (WorldFish Center) និយាយថាៈ "នៅក្នុងអាងទន្លេមេគង្គ គេពុំឃើញមានឧទាហរណ៏នៃច្រកឆ្លងកាត់ [ត្រី] ប្រកបដោយប្រសិទ្ធិភាពឡើយ"។[ក] ទស្សនៈនេះត្រូវបានឯកភាពដោយអ្នកវិទ្យាសាស្ត្រពាក់ព័ន្ធផ្សេងទៀតដែលអះអាងថា "គេពុំឃើញមានលទ្ធភាពដែលច្រកត្រីឆ្លងកាត់អាចធ្វើឱ្យមានភាពខុសគ្នាច្រើនចំពោះឥទ្ធិពលខ្ទប់ផ្លូវនៃទំនប់នេះឡើយ"។[ខ]

*<u>ឋានៈ RAMSAR</u>*

ដោយទទួលស្គាល់តម្លៃជីវៈចម្រុះពិភពលោកនៃជម្រកកោះ-ទន្លេស៊ីផាន់ដនដ៏ពិសេស រដ្ឋាភិបាលឡាវកំពុងពិចារណាស្នើដាក់តំបន់នេះចូលក្នុងអនុសញ្ញា RAMSAR ស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់អន្តរជាតិ (RAMSAR Convention on Wetlands of International Importance)។ ការកំណត់ RAMSAR នឹងគាំទ្រកិច្ចប្រឹងប្រែងការពារតំបន់នេះ និង ជម្រុញវិស័យទេសចរណ៍ ដែលនាំមកនូវអត្ថប្រយោជន៏សេដ្ឋកិច្ចច្រើនជូនដល់សហគមន៏ក្នុងមូលដ្ឋាន និង សេដ្ឋកិច្ចជាតិ។ នៅជាប់ព្រំដែនម្ខាងនៅក្នុងខេត្តស្ទឹងត្រែងប្រទេសកម្ពុជា ផ្នែកខាង

ជើងបំផុតនៃទន្លេមេគង្គត្រូវបានកំណត់ជាទីកន្លែង RAMSAR មួយក្នុងឆ្នាំ ១៩៩៩។ ប៉ុន្តែ ទំនប់ដនសាហុង គម្រាមកំហែងគុណសម្បត្តិរបស់តំបន់ស៊ីផាន់ដន និង អត្ថប្រយោជន៍ដែលឋានៈ RAMSAR អាចនាំមក។

*<u>ត្រីផ្សោត Irrawaddy</u>*

អន្លង់ទឹកជ្រៅវ៉ឺនញ៉ាង/អន្លង់ឈើទាល ដែលនៅខាងក្រោមខ្សែទឹកស៊ីផាន់ដនតែបន្តិចនៅព្រំដែនឡាវ-កម្ពុជា គឺជាជម្រកត្រីផ្សោត Irrawaddy ប្រហែល ១០។ នៅរដូវប្រាំង ត្រីផ្សោតទាំងនេះរស់នៅក្នុងអន្លង់ទឹកជ្រៅដែលនៅទីនោះមានត្រី។ ក្នុងរដូវវស្សា ត្រីផ្សោតចេញពីអន្លង់ទឹកជ្រៅ ដោយធ្វើចលនានៅក្នុងចម្ងាយតែពីរបីរយម៉ែត្រប៉ុណ្ណោះពីទីតាំងទំនប់។ ហ្វូងត្រីផ្សោត Irrawaddy នៃទន្លេមេគង្គ គឺជាត្រីផ្សោតជិតផុតពូជ ហើយនៅសល់មិនដល់ ១០០ ផង។ យោងតាមអង្គការ WWF ទំនប់ដនសាហុងអាចគម្រាមកំហែងការរស់រាននៃហ្វូងត្រីផ្សោត Irrawaddy នៅអន្លង់ទឹកជ្រៅវ៉ឺនញ៉ាង/អន្លង់ឈើទាល ដែលជាហ្វូងត្រីផ្សោតអចិន្ត្រៃយ៍តែមួយគត់របស់ប្រទេសឡាវ។[គ]

## ការធ្វើបំលាស់ទីកន្លែងត្រីតាមព្រែកហ៊ូសាហុងដែលគេបានស្គាល់

ខាងក្រោមនេះគឺជាការធ្វើបំលាស់ទីកន្លែងត្រីសំខាន់ៗនៅក្នុងតំបន់ល្បាក់ខោន ដែលការធ្វើបំលាស់ទីកន្លែងទាំងអស់នេះអាចត្រូវបានរារាំងមួយផ្នែកឬទាំងស្រុងដោយទំនប់ដនសាហុង។ គេក៏ឃើញមានការធ្វើបំលាស់ទីកន្លែងមិនសូវសំខាន់ផ្សេងទៀតផងដែរ ដែលមុខជារងផលប៉ះពាល់ជាមិនខាន។

**ពីខែ ធ្នូ ដល់ខែ កុម្ភៈ:** ប្រភេទត្រីទឹកសាបទំហំល្មមសំខាន់ៗមួយចំនួនធ្វើដំណើរចេញពីទន្លេសេកុង សេសាន និង ស្រែពក នៅក្នុងប្រទេសកម្ពុជានិងឡាវ ទៅកាន់ទន្លេមេគង្គនៅស្ទឹងត្រែងប្រទេសកម្ពុជា និង បន្ទាប់មកឡើងទៅកាន់ប្រទេសឡាវ។ ត្រីទាំងនេះឆ្លងកាត់តំបន់ល្បាក់ខោនតាមព្រែកហ៊ូសាហុង ហើយបន្ទាប់មកធ្វើដំណើរឆ្លងកាត់ប៉ាក់សេ និង ឡើងទៅលើទន្លេមេគង្គទៅកាន់ព្រំដែនឡាវនិងថៃ។ ការធ្វើបំលាស់ទីត្រីទាំងនេះ នឹងត្រូវបានរារាំងដោយទំនប់ដនសាហុង។ ជលផលផ្សេងទៀតនៅក្នុងទន្លេសេកុងក្នុងប្រទេសឡាវ ក៏មុខជាត្រូវរងផលប៉ះពាល់ដែរជាមិនខាន ដោយសារត្រីនៅទីនោះផ្លាស់ទីកន្លែងទៅមកនៅចន្លោះខ្សែទឹកខាងលើល្បាក់ខោន និង ទន្លេសេកុង។

**ពីខែ មករា ដល់ខែ មីនា:** ហ្វូងត្រីសំខាន់ធំៗនៃប្រភេទត្រីទឹកសាបតូចៗ ជាពិសេសប្រភេទត្រី *Henicorhynchus lobatus* (*ប៉ាសយ*) ធ្វើដំណើរឡើងលើពីបឹងទន្លេសាបនៅប្រទេសកម្ពុជាទៅកាន់ឡាវឆ្លងកាត់ល្បាក់ខោន និង ព្រែកហ៊ូសាហុង។ ដូចជាត្រីដែលបានរៀបរាប់ខាងលើអញ្ចឹងដែរ ត្រីទាំងនោះ ដែលមានសារៈសំខាន់ក្រៃលែងចំពោះជីវភាពរបស់ប្រជាជនដែលរស់នៅតាមដងទន្លេមេគង្គនៅភាគខាងត្បូងនិងកណ្តាលប្រទេសឡាវ មុខជាត្រូវបានរារាំងមិនឱ្យចូលប្រទេសឡាវដោយទំនប់ដនសាហុង។

**ខែ មេសា:** ប្រភេទត្រីទឹកសាបសំខាន់ធំៗ ពោលគឺប្រភេទត្រី *Cirrihnus microlepis* (*ប៉ាផោន*)

ធ្វើដំណើរឡើងទៅ ប៉ែកខាងលើទន្លេមេគង្គពីកម្ពុជាទៅកាន់ប្រទេសឡាវ ដោយឆ្លងកាត់តាមព្រែកហ៊ូសាហុង។

**ពីខែ មេសា ដល់ខែ ឧសភា:** ត្រីប្រាតូចៗប្រភេទ *Pangasius macronema* (*ប៉ាញ៉ូនធម្មតា*) ធ្វើដំណើរឡើងទៅប៉ែកខាងលើទន្លេមេគង្គពីកម្ពុជាចូលទៅប្រទេសឡាវឆ្លងកាត់តាមព្រែកហ៊ូសាហុងរៀងរាល់ឆ្នាំ។

**ពីខែ ឧសភា ដល់ខែ មិថុនា:** ត្រីប្រានៅក្នុងប្រភេទ Pangasiidae ធ្វើដំណើរឡើងទៅប៉ែកខាងលើទន្លេមេគង្គពីកម្ពុជាចូលទៅប្រទេសឡាវឆ្លងកាត់តាមតំបន់ល្បាក់ខោននិងព្រែកហ៊ូសាហុង។ ត្រីមួយប្រភេទនៃត្រីទាំងនេះ ពោលគឺត្រីប្រភេទ Pangasius krempfi (ប៉ាសួយហង់លឿង) ធ្វើដំណើរឡើងទៅប៉ែកខាងលើទន្លេមេគង្គតាំងពីតំបន់ដីសណ្តរទន្លេមេគង្គនៅប្រទេសវៀតណាម។

**ពីខែ ឧសភា ដល់ខែ មិថុនា:** ត្រីកាបធំៗដែលរងការគម្រាមកំហែង ប្រភេទ Probabus jullieni (ប៉ាអ៊ុនតាដេង) និង ប្រភេទ Probarbus labeamajor (ប៉ាអ៊ុនខាវ) ពងនៅក្នុងតំបន់ល្បាក់ខោន នៅជិតទីតាំងទំនប់ដនសាហុងដែលគេបានស្នើឡើង។

*ដកស្រង់ពី "ប៊ែរដ (Baird, I.G.) (ឆ្នាំ ១៩៩៦) ផលផលល្បាក់ខោន ផលផលនិងវប្បធម៌, គណៈកម្មការទន្លេមេគង្គ ២(២):១-៣។"*

## *វិស័យទេសចរណ៍*

ទំនប់ដនសាហុងនឹងគម្រាមកំហែងការកំសាន្តទេសចរណ៍សំខាន់ពីរនៃស៊ីផាន់ដន ពោលគឺ ត្រីផ្សោត Irrawaddy និង ទឹកជ្រោះខោនផាផេង។ គម្រោងនេះនឹងកាត់បន្ថយលំហូរទឹកចូលជ្រោះខោនផាផេងដោយបង្វែរទឹកទៅឱ្យទំនប់ដើម្បីផលិតអគ្គិសនី។ គេក៏ឃើញមានការរំខានរយៈពេលខ្លីផងដែរចំពោះតំបន់នេះនៅក្នុងអំឡុងពេលសាងសង់គម្រោង និង ផលប៉ះពាល់អចិន្ត្រៃយ៍លើសោភ័ណភាពដែលបណ្តាលមកពីហេដ្ឋារចនាសម្ព័ន្ធទំនប់ដែលក៏នឹងធ្វើឱ្យខូចខាតដល់ការទាក់ទាញភ្ញៀវទេសចរនៃតំបន់នេះផងដែរ។

## *ការបារម្ភរបស់សាធារណៈជនអំពីគម្រោងដនសាហុង*

សំណើអភិវឌ្ឍគម្រោងដនសាហុងបាននាំឱ្យមានការបារម្ភច្រើននៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សា អ្នកមានអាជីពអភិវឌ្ឍន៍ និង សាធារណៈជនទូទៅទាំងនៅក្នុងតំបន់ទន្លេមេគង្គនិងអន្តរជាតិ។[ឃ] កាលពីខែ មេសា ឆ្នាំ ២០០៧ នៅពេលដែលផែនការរៀបចំគម្រោងត្រូវបានគេដឹងឮជាលើកដំបូង អង្គការមិនមែនរដ្ឋាភិបាលចំនួន ២៨ បានផ្ញើលិខិតចំហរមួយជូនរដ្ឋាភិបាលឡាវ គណៈកម្មការទន្លេមេគង្គ និង រដ្ឋាភិបាលជាសមាជិកគណៈកម្មការទន្លេមេគង្គ ដោយអំពាវនាវសុំឱ្យពិចារណាគម្រោងនេះឡើងវិញ។[ង] ក្នុងខែ ឧសភា ឆ្នាំ ២០០៧ អ្នកវិទ្យាសាស្ត្រចំនួន ៣៤ នាក់ បានផ្ញើលិខិតមួយជូនរដ្ឋាភិបាលឡាវដែលជម្រុញឱ្យអ្នកធ្វើសេចក្តីសម្រេច "ពិចារណានូវទម្ងន់នៃភស្តុតាងវិទ្យាសាស្ត្រដែលនឹងបង្ហាញថាគម្រោងដនសាហុងគឺមានលក្ខណៈវិនាសដ៏ធំធេងដែល

សូម្បីតែថ្លៃចំណាយសេដ្ឋកិច្ច (រួមទាំងជីវភាពផង) ក៏មានទម្ងន់ជាងអត្ថប្រយោជន៍សុទ្ធដែរ - សូម្បីតែនៅមុនពេលដែលផលប៉ះពាល់បរិស្ថាន ត្រូវបានគេពិចារណាទៀតផង។[៥]



*ឧបករណ៍ចាប់ត្រីនៅក្នុងព្រែកហ៊ូសាហុង ដែលនៅខាងលើខ្សែទឹកជាប់នឹងទីតាំងទំនប់* (Carl Middleton, International Rivers)

ក្រុមហ៊ុនអភិវឌ្ឍគម្រោងពោលគឺ MFCB នៅមិនទាន់បានបញ្ចេញជាសាធារណៈនៅឡើយ នូវឯកសារគម្រោងសំខាន់ៗទាក់ទិននឹងបរិស្ថាននិងសង្គម។ មកដល់ពេលនេះ ប្រជាជនក្នុងមូលដ្ឋានបានទទួលព័ត៌មានមិនត្រឹមត្រូវនិងមិនគ្រប់គ្រាន់អំពីផលប៉ះពាល់អវិជ្ជមាននៃទំនប់ដែលអាចកើតឡើង។ ប្រជាជនខាងក្រោមខ្សែទឹកនៅក្នុងប្រទេសកម្ពុជាបានទទួលព័ត៌មានអំពីគម្រោងនេះកាន់តែតិចថែមទៀត និង អំពីប្រការដែលថាតើគម្រោងនេះនឹងប៉ះពាល់ពួកគេយ៉ាងដូចម្តេច។

## អនុសាសន៍

ទំនប់ដនសាហុងគឺមិនសមហេតុផលទេ។ សម្រាប់អគ្គិសនីកម្លាំងមិនលើសពី ៣៦០ មេហ្គាវ៉ាត់ ទំនប់នេះមុខជាគម្រាមកំហែងជលផលនេសាទពាណិជ្ជកម្មនិងចិញ្ចឹមជីវិតដ៏សំខាន់ក្រៃលែង ក៏ដូចជាភោគទ្រព្យជីវសាស្ត្រ និងឧស្សាហកម្មទេសចរណ៍នៃតំបន់នេះផងដែរ។ ទោះបីជាមានការគម្រាមកំហែងធ្ងន់ធ្ងរទាំងនេះក្តី ក៏មានព័ត៌មានតិចតួចណាស់ដែលបានបញ្ចេញជូនសាធារណៈជន។ ការវាយតម្លៃលើផលប៉ះពាល់ដែលអាចកើតឡើងនៃទំនប់វារីអគ្គិសនីនេះលើជលផលទន្លេមេគង្គ ដែលត្រូវបានបោះពុម្ពផ្សាយដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គក្នុងឆ្នាំ ១៩៩៤ បានពិពណ៌នាស៊ីផាន់ដនថាជា "តំបន់អេកូឡូស៊ីពិសេសមួយដែលគឺជាពិភពអតិសុខុមប្រាណនៃទន្លេមេគង្គក្រោមទាំងមូល" និង បានចង្អុលបង្ហាញថា "ទីកន្លែងដូចនេះគឺកម្រមានណាស់នៅក្នុងធម្មជាតិ ដែលគេគប្បីខិតខំអភិរក្សល្បាក់ខោន [ស៊ីផាន់ដន] ទាំងអស់កុំឱ្យមានការអភិវឌ្ឍន៍អ្វីឡើយ។"[៦]

ជំនួសឱ្យការសាងសង់ទំនប់ដនសាហុងដែលធ្វើឱ្យខូចខាតដល់ជលផល និង ជីវភាពរស់នៅដែលពឹងផ្អែកលើជលផល ផែនការកំណត់តំបន់ស៊ីផាន់ដនជាទីកន្លែង RAMSAR មួយ គប្បីជម្រុញទៅមុខ ហើយទេសចរណ៍បរិស្ថានគប្បីត្រូវបានជម្រុញ ដែលនឹងផ្តល់ជូនអត្ថប្រយោជន៍កម្រិតតំបន់ ជាតិ និង មូលដ្ឋាន។

**ឯកសារយោង**

[ក] មជ្ឈមណ្ឌលមច្ឆាជាតិពិភពលោក (WorldFish Center) (ឆ្នាំ ២០០៧) "ទំនប់ដនសាហុង និង ផលផលទន្លេមេគង្គ" *ដំឡើង វិទ្យាសាស្ត្រមួយពីមជ្ឈមណ្ឌលមច្ឆាជាតិពិភពលោក*។

[ខ] លិខិតពីអ្នកវិទ្យាសាស្ត្រដែលបារម្ភអំពីកិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃទន្លេមេគង្គ ជូនរដ្ឋាភិបាលនិងអង្គការអន្តរជាតិនានាដែលទទួលបន្ទុកលើការគ្រប់គ្រងនិងអភិវឌ្ឍន៍ទន្លេមេគង្គ, កម្មវត្ថុ: ការបារម្ភអំពីទំនប់ដនសាហុង ដែលត្រូវបានធ្វើផែនការសម្រាប់ទន្លេមេគង្គនៅក្នុងតំបន់ល្បាក់ខោន, ស្រុកខុង ខេត្តចំប៉ាសាក់ ភាគខាងត្បូង ប្រទេសឡាវ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៧។

[គ] អង្គការ WWF (ឆ្នាំ ២០០៧) ទំនប់ដនសាហុង និង ត្រីផ្សោត Irrawaddy, សេចក្តីសង្ខេបវិទ្យាសាស្ត្រមួយពីអង្គការ WWF ។

[ឃ] សូមមើល www.livingriversiam.org/mk/sub_lowerdam.html ដើម្បីឯកសារពេញលេញអំពីការផ្សាយសារព័ត៌មាន។

[ង] http://www.internationalrivers.org/files/Don%20Sahong%20scientists%20May%202007.pdf

[ច] ម៉ាក ហ៊ីល និង ស៊ូហ្សាន (Mark T. Hill and Susan A.)។ ហ៊ីល, ឆ្នាំ ១៩៩៤, ប្រព័ន្ធអេកូឡូស៊ីជលផល និង វារីអគ្គិសនីនៅក្នុងទន្លេមេគង្គ: ការវាយតម្លៃលើគម្រោងដំណើរការទន្លេ (An Evaluation of Run-of-the-River Projects)។ លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ បាងកក ទំព័រ ៩០។

ព័ត៌មានបន្ថែម សូមមើល: http://www.internationalrivers.org/en/southeast-asia/mekong-mainstream-dams/don-sahong

***សម្ព័ន្ធទន្លេកម្ពុជា*** *គឺជាសម្ព័ន្ធនៃអង្គការសង្គមស៊ីវិលដែលធ្វើការដើម្បីការពារនិងស្តារប្រព័ន្ធអេកូឡូស៊ីទន្លេ និង ជីវភាពរស់នៅផ្អែកលើទន្លេនៅប្រទេសកម្ពុជា។ ព័ត៌មានបន្ថែមសូមទំនាក់ទំនង តាមរយៈអ៊ីមែល ngoforum@ngoforum.org.kh គេហទំព័រ www.ngoforum.org.kh*

***អង្គការទន្លេអន្តរជាតិ (International Rivers)*** *គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលការពារទន្លេ និង ការពារសិទ្ធិរបស់សហគមន៍ទាំងឡាយដែលពឹងអាស្រ័យលើទន្លេ។ អង្គការទន្លេអន្តរជាតិប្រឆាំងនឹងទំនប់ដែលមានលក្ខណៈវិនាស និង គម្រូអភិវឌ្ឍន៍ដែលទំនប់ទាំងនេះជម្រុញ និង លើកទឹកចិត្តឱ្យមានមធ្យោបាយប្រសើរជាងដើម្បីបំពេញសេចក្តីត្រូវការទឹកនិងថាមពលរបស់ប្រជាជន និង ការការពារទល់នឹងទឹកជំនន់ដ៏វិនាស។ សម្រាប់ព័ត៌មានបន្ថែមសូមចូលគេហទំព័រ www.internationalrivers.org*